ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# គោលការណ៍ណែនាំ
# សម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
# រុក្ខាប្រមាញ់ និងនេសាទ ឃុំ

**រៀបចំដោយ:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបត្ថម្ភការបោះពុម្ព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៩

# អារម្ភកថា

កសិកម្មជាវិស័យមួយដ៏សំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកជាវិស័យអាទិភាពមួយ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធម៌ សុវត្ថិភាពស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ជាមួយគ្នានេះការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាអនុវិស័យផ្សេងៗទៀតដែលមានតួនាទីសំខាន់ក្នុងការចូលរួមគាំទ្រ និងអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឱ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព។

បច្ចុប្បន្នប្រព័ន្ធនិងសេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា ការខ្វះខាតធនធានមនុស្ស ថវិកា លិខិតបទដ្ឋានគតិយុត្ត សម្ភារ មធ្យោបាយផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទ វិធីសាស្ត្រសមស្របសម្រាប់ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលការណ៍ណែនាំស្តីពីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ដោយអនុលោមតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ដែលបានកំណត់ប្រភេទនៃភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបួនប្រភេទក្នុងនោះភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ គឺជាអ្នកអនុវត្តជួរមុខ ដែលធ្វើការផ្ទាល់ជាមួយកសិករនៅមូលដ្ឋាន ហើយមានតួនាទីសំខាន់ក្នុងការទទួល និងផ្ទេរនូវព័ត៌មានបច្ចេកវិទ្យាថ្មីៗដែលពាក់ព័ន្ធទៅនឹងផលិតកម្មកសិកម្ម បង្កើតបណ្តាញព័ត៌មានក្នុងការទំនាក់ទំនងរវាងកសិករ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលជាអ្នកសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានា។

គោលការណ៍ណែនាំនេះសម្រាប់ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន

និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាកសិកម្មថ្មីៗ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្លាស់ប្តូរបទពិសោធន៍ ការចែករំលែកចំណេះដឹងស្របតាមស្ថានភាពវិវត្តន៍នៃសកលភាវូបនីយកម្ម ពាណិជ្ជូបនីយកម្ម រួមចំណែកក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្មនៅលើទីផ្សារប្រកបដោយប្រសិទ្ធភាពដើម្បីជំរុញកំណើនសេដ្ឋកិច្ចគ្រួសារកសិករ និងសហគមន៍មូលដ្ឋាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនឿថាគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ដែលបានរៀបចំបង្កើតឡើងនេះនឹងក្លាយជាឯកសារគោលមួយយ៉ាងសំខាន់ និងជាផែនទីបង្ហាញផ្លូវ ឆ្ពោះទៅរកសកម្មភាពផលិតកម្មសមស្រប សំដៅលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជាឱ្យកាន់តែមានការអភិវឌ្ឍបន្ថែមទៀត នាពេលអនាគត។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមឱ្យគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ កសិករ និងសហគមន៍មូលដ្ឋាន ចូលរួមសហការអនុវត្តគោលការណ៍ណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ៨រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# មាតិកា ទំព័រ


១. សេចក្តីផ្តើម............................................................................ ១
២. គោលបំណង............................................................................ ៣
៣. គោលការណ៍ក្នុងការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ............................................................................ ៤
៣.១ លក្ខណៈវិនិច្ឆ័យ............................................................................ ៥
៣.២ នីតិវិធីក្នុងការជ្រើសរើស............................................................................ ៥
៣.៣ ការគាំទ្របច្ចេកទេស និងថវិកា............................................................................ ៧
៣.៤ ការទទួលស្គាល់ជាភ្នាក់ងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ......... ១០
៣.៥ ការពិនិត្យ តាមដាន និងវាយតម្លៃលើគុណភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ............................................................................ ១០
៤. តួនាទី និងភារកិច្ច............................................................................ ១១
៥. សន្និដ្ឋាន............................................................................ ១៤
៦. ឧបសម្ព័ន្ធទី១ ប្រធានបទបណ្តុះបណ្តាល............................................................................ ១៦
៧. ឧបសម្ព័ន្ធទី២ ទម្រង់ការជូនដំណឹងដល់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ............................................................................ ១៧
៨. ឧបសម្ព័ន្ធទី៣ ទម្រង់ការជូនដំណឹងជាសាធារណៈ............................................................................ ១៨
៩. ឧបសម្ព័ន្ធទី៤ ទម្រង់បញ្ជីឈ្មោះបេក្ខជនប្រឡង............................................................................ ២០
១០. ឧបសម្ព័ន្ធទី៥ ទម្រង់ការជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការប្រលងជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ............................................................................ ២១
១១. ឧបសម្ព័ន្ធទី៦ ទម្រង់បញ្ជីរាយនាមបេក្ខជនបេក្ខនារីដែលប្រលងជាប់ជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ............................................................................ ២២
១២. ឧបសម្ព័ន្ធទី៧ ទម្រង់ពាក្យសុំចូលបម្រើការងារ............................................................................ ២៣
១៣. ឧបសម្ព័ន្ធទី ៨ ទម្រង់វាយតម្លៃលទ្ធផលបំពេញការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ............................................................................ ២៦

## ១. សេចក្តីផ្តើម

បច្ចុប្បន្នលទ្ធភាពនៃការទទួលបានព័ត៌មានលើការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកបដោយគុណភាពសម្រាប់កសិករកម្ពុជាតាមរយៈនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដែលអ្នកជំនាញផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាំងនោះភាគច្រើនបានផ្តល់សេវាកម្មទៅតាមបណ្តារាជធានីខេត្តនានា ប៉ុន្តែនៅមានបញ្ហាប្រឈមនៅឡើយ។ បញ្ហាប្រឈមទាំងនេះរួមមាន (១)ធនធានដែលអាចប្រើប្រាស់បានដើម្បីធានាបានការបណ្តុះបណ្តាលនៅមានកំណត់ (២)ចំនួនមន្ត្រីផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅមិនទាន់គ្រប់គ្រាន់ និងសមត្ថភាពសម្រាប់អនុវត្តការងារនៅតាមជនបទនៅមានកម្រិត ដែលមិនអាចឆ្លើយតបទៅនឹងតម្រូវការកសិករ។

តាមការរីកចម្រើននៃវិស័យកសិកម្ម ការប្រកបរបរកសិកម្មជាលក្ខណៈគ្រួសារបានផ្លាស់ប្តូរទៅជាការធ្វើកសិកម្មបែបពាណិជ្ជកម្ម គឺត្រូវប្រើប្រាស់ធាតុចូលឱ្យកាន់តែតិចដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងផលិតផលរបស់កសិករនៅទូទាំងប្រទេសមានការប្រកួតប្រជែងនៅលើទីផ្សារ ដែលពេលខ្លះធ្វើឱ្យផលិតផលទាំងនោះអន់គុណភាពដូចនេះការកែច្នៃផលិតផល គឺជាបញ្ហាមួយដ៏សំខាន់ដែលតម្រូវឱ្យអ្នកផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទនិងអ្នកបច្ចេកទេសកសិកម្មគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់បំផុស និងជំរុញការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេសសមស្របតាមរយៈការបណ្តុះបណ្តាល បង្ហាត់បង្ហាញដល់កសិករឱ្យមានចំណេះដឹង និងជំនាញសម្រាប់កសិករយកទៅអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

តាមស្ថិតិឆ្នាំ២០១៩ មន្ត្រីផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទដែលកំពុងអនុវត្ត និងសម្របសម្រួលការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅកម្ពុជា នៅថ្នាក់ជាតិមានមន្ត្រីចំនួន៥៩នាក់ នៅថ្នាក់ខេត្តចំនួន១៣៥នាក់ នៅថ្នាក់ស្រុកចំនួន៨០០នាក់ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំចំនួន៨៤១

នាក់ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ភូមិចំនួន១០១៥១នាក់ គឺមិនអាចឆ្លើយតបទៅនឹងចំនួនគ្រួសារកសិករ ២,១លានគ្រួសារ(ជំរឿនកសិកម្មឆ្នាំ ២០១៣) ដែលគោលនយោបាយផ្សព្វផ្សាយកសិកម្ម បានចង្អុលបង្ហាញថា១០០០ គ្រួសារកសិករ តម្រូវឱ្យមានមន្ត្រីផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១នាក់ សម្រាប់ដឹកនាំសម្របសម្រួលនិងអនុវត្តការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការអនុវត្តកសិកម្មល្អថ្មីៗដល់កសិករ និងសហគមន៍កសិកម្ម។ បច្ចុប្បន្នវិស័យឯកជនបាន និងកំពុងបញ្ចេញសកម្មភាពផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ យ៉ាងសកម្មដែលភាគច្រើនបានផ្តល់ទៅឱ្យកសិដ្ឋានដែលមានទ្រង់ទ្រាយជាលក្ខណៈពាណិជ្ជកម្ម។ទន្ទឹមនេះដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនបាន បណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតាមមូលដ្ឋាន ដោយសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមបណ្តារាជធានីខេត្ត។ គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ក៏បានចង្អុលបង្ហាញឱ្យបង្កើតគោលការណ៍ណែនាំជាច្រើនដែលតម្រូវឱ្យនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រចេញពីការផ្សព្វផ្សាយដែលជំរុញផលិតកម្មតាមបែបផ្គត់ផ្គង់លក្ខណៈគ្រួសារឆ្ពោះទៅរកការផ្សព្វផ្សាយលក្ខណៈពាណិជ្ជកម្មតាមតម្រូវការទីផ្សារ ការប្រកួតប្រជែង ការបង្កើនតម្លៃបន្ថែម និងការធានានិរន្តរភាព ព្រមទាំងការផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមបែបពហុនិយមតាមរយៈ ការបង្កើតភាពជាដៃគូ កិច្ចសហការ និងបណ្តាញទាក់ទងគ្នាដែលជាទិដ្ឋភាពដ៏សំខាន់នៃសេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាចែងថា ភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទយ៉ាងហោចត្រូវមាន០៤ ប្រភេទគឺ ៖ (១)អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(២) ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៣)ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ និង(៤)ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទភូមិ។ ដើម្បី

ឱ្យអ្នកផ្តល់សេវាផ្សព្វផ្សាយទាំងអស់អាចបំពេញតួនាទីរបស់ខ្លួនបានជោគជ័យត្រូវមានការកំណត់កម្រិតអប្បបរមាក្នុងការអប់រំ ឬការបណ្តុះបណ្តាលម្រាប់ប្រភេទនីមួយៗ។

ក្នុងការធានាគុណភាពការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាពនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលការណ៍ណែនាំជាខ្នាតគំរូមួយដើម្បីជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅកម្ពុជា។

## ២. គោលបំណង

គោលបំណងរួមនៃឯកសារនេះ ដើម្បីប្រើប្រាស់សម្រាប់ស្ថាប័នពាក់ព័ន្ធដូចជាមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដែលតម្រូវការចាំបាច់ក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដល់កសិករ។ការរៀបចំគោលការណ៍ណែនាំនេះដើម្បីជួយដល់អ្នកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ក្នុងការរៀបចំផែនការ និងអនុវត្តន៍គម្រោងសកម្មភាពផ្សព្វផ្សាយកសិកម្មប្រកបដោយគុណភាព ក៏ដូចជាអ្នកនៅកៀកកសិករងាយស្រួលផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលយកព័ត៌មានត្រឡប់ពីកសិករមកប្រាប់ដល់អ្នកជំនាញនិងអ្នកស្រាវជ្រាវវិញ។ គោលបំណងសំខាន់នៃគោលការណ៍ណែនាំនេះរួមមាន៖

- បង្កើតជាឯកសារខ្នាតគំរូមួយ ដើម្បីជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំឱ្យមានគុណវុឌ្ឍិ
- អភិវឌ្ឍន៍និងគ្រប់គ្រងធនធានមនុស្សក្នុងការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ជំរុញសេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទឱ្យកាន់តែមានប្រសិទ្ធភាពនិងនិរន្តរភាព។

## ៣. គោលការណ៍ក្នុងការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

ដើម្បីទទួលបាននូវភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ប្រកបដោយគុណភាពចាំបាច់ត្រូវអនុវត្តវិធីសាស្រ្តដូចជាការពិនិត្យលើលក្ខណៈវិនិច្ឆ័យតួនាទីភារកិច្ច ការបណ្តុះបណ្តាលពីវិធីសាស្រ្តផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបច្ចេកទេសកសិកម្ម ការទទួលស្គាល់ជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ គោលការណ៍ណែនាំនេះគឺជាដំណើរការប្រទាក់ក្រឡាគ្នាមួយដែលតម្រូវឱ្យអ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធទាំងអស់ចូលរួមសហការអនុវត្តផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹងក្នុងការជ្រើសរើស និងអភិវឌ្ឍន៍ធនធានមនុស្សលើការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ខាងក្រោមនេះ បង្ហាញពីជំហានក្នុងការជ្រើសរើសនិងអភិវឌ្ឍន៍សមត្ថភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ៖

**ជំហានសំខាន់ៗក្នុងការជ្រើសរើស ភ.ផ.ក.រ.នឃុំ**




១. លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស

២. នីតិវិធីក្នុងការជ្រើសរើស

៣. ការគាំទ្របច្ចេកទេសនិងថវិកា

៤. ការទទួលស្គាល់ (៥) ការពិនិត្យលើគុណវុឌ្ឍិភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ។

## ៣.១ លក្ខណៈវិនិច្ឆ័យ

បេក្ខជន បេក្ខនារីដែលត្រូវជ្រើសរើស និងបណ្ដុះបណ្ដាលក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំត្រូវមានលក្ខណៈសម្បត្តិមួយចំនួនដូចខាងក្រោម៖

### ❖ លក្ខណៈសម្បត្តិគោល

- ជនជាតិខ្មែរ មានអាយុចាប់ពី១៨ឆ្នាំឡើង
- កម្រិតវប្បធម៌ទាបបំផុតបញ្ចប់កម្រិតបឋមសិក្សា ឬ ចេះអាន និងសរសេរភាសាខ្មែរច្បាស់លាស់
- មានបទពិសោធន៍លើការងារកសិកម្មយ៉ាងតិច២ឆ្នាំ
- មានទីលំនៅពិតប្រាកដនៅក្នុងភូមិ ឃុំគោលដៅ

### ❖ លក្ខណៈសម្បត្តិបំពេញបន្ថែម

- ជាភ្នាក់ងារសុខភាពសត្វភូមិ
- គ្រូបង្គោល ឬគ្រូវិធានការចម្រុះគ្រប់គ្រងដំណាំ( IPM)
- មានវិញ្ញាបនបត្របញ្ជាក់ការសិក្សាពាក់ព័ន្ធការងារកសិកម្ម
- ស្ម័គ្រចិត្តបម្រើការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទតាមរយៈការចែករំលែកចំណេះ ដឹង និងបទពិសោធន៍ជាមួយអ្នកភូមិ
- ស្ត្រីត្រូវបានលើកទឹកចិត្ត និងផ្ដល់អាទិភាព។

- **កំណត់សំគាល់**: បេក្ខជន បេក្ខនារីដែលមានលក្ខណៈសម្បត្តិគោលត្រូវមានលក្ខណៈសម្បត្តិបំពេញបន្ថែមមួយយ៉ាងតិច។

## ៣.២ នីតិវិធីក្នុងការជ្រើសរើស

ការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំត្រូវមានសកម្មភាពចម្បងៗមួយចំនួនដូចខាងក្រោម៖

- បង្កើតគណៈកម្មការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់

និងនេសាទឃុំ៖ គណៈកម្មការនេះមានសមាសភាពចូលរួមពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធផ្សេងៗយ៉ាងហោចណាស់ចំនួន៥នាក់ ( សមាជិកគណៈកម្មការត្រូវជាចំនួនសេស )។

- ប្រជុំគណៈកម្មការរៀបចំឯកសារជូនដំណឹងស្តីពីការជ្រើសរើស
- បិទប្រកាសជ្រើសរើស ដោយទុករយៈពេលយ៉ាងយូរបំផុត១៤ថ្ងៃនៃថ្ងៃធ្វើការសម្រាប់បេក្ខជន បេក្ខនារីដាក់ពាក្យ។ ក្នុងករណីមិនមានបេក្ខជនឬបេក្ខនារីដាក់ពាក្យគ្រប់គ្រាន់ គណៈកម្មការត្រូវធ្វើការបិទប្រកាសជាលើកទី២ដោយទុករយៈពេល១៤ថ្ងៃនៃថ្ងៃធ្វើការដដែល។
- គណៈកម្មការធ្វើការវាយតម្លៃបេក្ខជនបេក្ខនារីដែលបានដាក់ពាក្យស្នើសុំសម្រាប់ធ្វើការសម្ភាសន៍
- ជូនដំណឹងដល់បេក្ខជន ឬបេក្ខនារីដែលត្រូវសម្ភាសន៍
- ដំណើរការសម្ភាសន៍ និងប្រកាសលទ្ធផល និង
- ចុះកិច្ចសន្យាបម្រើការងារ។

ការសម្ភាសន៍បេក្ខជន ឬបេក្ខនារីត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា៖

**❖ ចំណេះដឹង**

- មានបទពិសោធន៍ និងអនុវត្តជាក់ស្តែងការងារកសិកម្មទទួលបានជោគជ័យ
- យល់ដឹងពីបច្ចេកទេសកសិកម្ម និងបរិស្ថាន
- មានទំនាក់ទំនង និងប្រាស្រ័យទាក់ទងល្អ
- មានចំណេះដឹងផ្នែកបច្ចេកវិទ្យា ឬព័ត៌មានវិទ្យា។

**❖ ជំនាញ និងលទ្ធភាព**

- មានលទ្ធភាពក្នុងការគ្រប់គ្រង ដឹកនាំក្រុម និងសហគមន៍
- មានជំនាញក្នុងការទំនាក់ទំនងកសិករនៅមូលដ្ឋាន

- មានជំនាញក្នុងការនិយាយជាសាធារណៈ
- មានលទ្ធភាពក្នុងការរៀបចំនិងសម្របសម្រួលកិច្ចប្រជុំឬព្រឹត្តិការណ៍ផ្សេងៗ
- ជំនាញវិភាគ និងដោះស្រាយបញ្ហាទាក់ទងទៅនឹងការងារកសិកម្ម
- ជំនាញក្នុងការកែច្នៃផលិតផលទៅតាមតម្រូវការទីផ្សារ។

❖ **គុណតម្លៃ និងអាកប្បកិរិយា**

- មានឆន្ទៈក្នុងការផ្ទេរ ចែករំលែកចំណេះដឹងនិងរៀនសូត្រពីកសិករដទៃទៀត
- មានគំនិតផ្តួចផ្តើមក្នុងការដោះស្រាយបញ្ហាផលប្រយោជន៍ក្នុងសហគមន៍
- មានការគោរពនិងឱ្យតម្លៃពីកសិករដទៃ
- មានសមត្ថភាពក្នុងការផ្លាស់ប្តូរឥរិយាបថរបស់សហគមន៍
- មានឆន្ទៈក្នុងការសិក្សាស្រាវជ្រាវ
- ជាអ្នកស្ម័គ្រចិត្ត។

## ៣.៣ ការគាំទ្របច្ចេកទេស និងថវិកា

ដើម្បីឱ្យភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំអាចបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាពល្អ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនត្រូវផ្តល់ការគាំទ្រទាំងបច្ចេកទេស និងថវិកា។

❖ **ការគាំទ្របច្ចេកទេស**

ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំត្រូវឆ្លងកាត់ការបណ្តុះបណ្តាលពីវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជំនាញបច្ចេកទេស ដែលរៀបចំនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

❖ **ការគាំទ្រថវិកា**

ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ គឺជាមន្ត្រីកិច្ចសន្យា

របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំ/សង្កាត់ ឬដៃគូអភិវឌ្ឍន៍ ឬវិស័យឯកជន។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ សម្ភារ និងមធ្យោបាយផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងដំណើរការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពីស្ថាប័នសាមីដែលជ្រើសរើស។

❖ **ប្រធានបទបណ្តុះបណ្តាល**

ដើម្បីក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ សិក្ខាកាមត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលចន្លោះពេលពី២ខែទៅ៤ខែ ដោយគិតបញ្ចូលទាំងការងារអនុវត្តជាក់ស្តែង ២ សប្តាហ៍ សរុបចំនួនម៉ោង ២៩៤ម៉ោង។ ប្រធានបទបណ្តុះបណ្តាលត្រូវផ្តោតលើវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម ៤០% ជំនាញបច្ចេកទេសដែលស្របជាមួយការប្រែប្រួលអាកាសធាតុ និងកសិកម្ម វៃឆ្លាត៦០%។ ប្រធានបទដែលត្រូវបណ្តុះបណ្តាលមានដូចខាងក្រោម៖

❖ វិធីសាស្ត្រផ្សព្វផ្សាយ (៤០% = ៩០ម៉ោង)

ក. លំនាំដើមនៃការផ្សព្វផ្សាយនៅកម្ពុជា

ខ. ឧបករណ៍ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ការកសាងផែនការ សកម្មភាពផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការតាមដាននិងវាយតម្លៃការងារផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- គេហទំព័រផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទនិងវិធីសាស្ត្រប្រើប្រាស់
- ការរៀនសូត្រពីកសិករទៅកសិករ
- យេនឌ័រក្នុងការងារផ្សព្វផ្សាយ និងការបង្កើនសិទ្ធិអំណាចដល់ស្ត្រី
- ដំណើរការប្រាស្រ័យទាក់ទង
- ជំនាញសម្របសម្រួល និងការដឹកនាំក្រុម

- ការវាយតម្លៃតម្រូវការកសិករ
- វិធីសាស្រ្តសរសេរករណីសិក្សា
- ការចងក្រងបណ្តុំអាជីវកម្មកសិកម្មនិងផ្សារភ្ជាប់ឆ្ពោះទៅទីផ្សារ
- ផែនការអាជីវកម្ម និងការកត់ត្រាចំណូលចំណាយ
- ការសរសេររបាយការណ៍ និងវាយតម្លៃការអនុវត្តនៅទីវាល។

❖ **ជំនាញបច្ចេកទេសដែលសមស្របជាមួយការប្រែប្រួលអាកាសធាតុ ការអនុវត្តកសិកម្មល្អ និងកសិកម្មវៃឆ្លាត (ប្រែប្រួលទៅតាមតម្រូវការមូលដ្ឋាន)**៦០% = ១៣៤ម៉ោង)

ក. ទស្សនទាននៃការប្រែប្រួលអាកាសធាតុ និងកសិកម្មវៃឆ្លាតធន់ទៅនឹងអាកាសធាតុ

ខ. ផលិតកម្មដំណាំ

គ. សាកវប្បកម្ម

ឃ. ផលិតកម្ម និងបសុព្យាបាល

ង. ជលផល

ច. ព្រៃឈើ

❖ **សិក្ខាកាមចុះអនុវត្តជាក់ស្តែង តាមមូលដ្ឋាន និងរបាយការណ៍ (ហាត់ការ)(៧០ ម៉ោង )**

**សំគាល់៖**

**ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលសិក្ខាកាមត្រូវចុះហាត់ការនៅមូលដ្ឋានដែលសាមីខ្លួនធ្វើការចំនួន២ដង។**

## ៣.៤ ការទទួលស្គាល់ជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

ក្រោយពីបណ្តុះបណ្តាលបានបញ្ចប់ សិក្ខាកាមនឹងទទួលបានវិញ្ញាបនបត្រ បញ្ជាក់ការទទួលស្គាល់ពីនាយកដ្ឋានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ដើម្បីក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជូនដំណឹងពីសមាសភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំដល់ នាយកដ្ឋានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងអាជ្ញាធរពាក់ព័ន្ធដែលសាមីខ្លួនបំពេញការងារ។

## ៣.៥ ការពិនិត្យ តាមដាន និងវាយតម្លៃលើគុណភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

ការតាមដាន និងវាយតម្លៃលើគុណភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំជាផ្នែកមួយសំខាន់នៃការគ្រប់គ្រង ការផ្តល់ទំនុកចិត្ត និង ការពង្រឹងសមត្ថភាព ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ក្នុងការចូលរួមធ្វើផែនការ ការអនុវត្តសកម្មភាពផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការសម្របសម្រួល និងសហការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការតាមដាននិងវាយតម្លៃលើលទ្ធផលអនុវត្តការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ជួយជំរុញការអនុវត្តកម្មវិធី ឬគម្រោងឱ្យបានរលូនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទរាជធានីខេត្តជាអ្នកតាមដានវាយតម្លៃ និងបញ្ជាក់ពីសមត្ថភាពក្នុងបំពេញការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំរៀងរាល់មួយឆ្នាំម្តង។

ផ្អែកលើរបាយការណ៍វឌ្ឍនភាពក្នុងការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អ្នកផ្តល់សេវាផ្សព្វផ្សាយ ត្រូវរៀបចំបូកសរុប និងរាយការណ៍ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវផ្ញើជូនមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៤. តួនាទី និងភារកិច្ច

ដើម្បីជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទឃុំប្រកបដោយសមត្ថភាព និងគុណភាពខ្ពស់ក្នុងការបំពេញការងារស្ថាប័នពាក់ព័ន្ធត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

❖ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- រៀបចំគោលការណ៍ណែនាំ និងផ្សព្វផ្សាយស្តីពីសារៈសំខាន់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំដល់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធ
- សហការជាមួយនាយកដ្ឋានជំនាញ រៀបចំឯកសារបច្ចេកទេស និងផ្តល់វគ្គបណ្តុះបណ្តាលក្នុងករណីចាំបាច់
- ប្រមូល ចងក្រង ធ្វើបច្ចុប្បន្នភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ និងដាក់បញ្ចូលទៅក្នុងគេហទំព័រនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមដានប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំ
- តាមដានវាយតម្លៃគុណភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ។

❖ **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្ត**

- សម្របសម្រួលការរៀបចំផែនការថវិកាសម្រាប់ជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ
- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជ្រើសរើសធនធានមនុស្សដើម្បីបណ្តុះបណ្តាល

- បណ្តុះបណ្តាល បច្ចេកទេស និងគាំទ្រថវិកា សម្ភារផ្សេងៗដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ
- សម្របសម្រួលក្នុងការបង្កើតគណៈកម្មការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ
- សម្របសម្រួល ក្នុងការជ្រើសរើសភ្នាក់ងារ ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ
- តាមដាន វាយតម្លៃលទ្ធផលរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំប្រចាំឆ្នាំ និងផ្ញើជូននាយកដ្ឋានផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទឃុំ និងផ្ញើរមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទជាប្រចាំ( រៀងរាល់មួយឆ្នាំម្តង )
- **តួនាទីគណកម្មការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ**
- រៀបចំនីតិវិធីនៃការជ្រើសរើស
- រៀបចំលក្ខណៈវិនិច្ឆ័យស្របតាមគោលការណ៍ណែនាំ
- រៀបចំលិខិតជូនដំណឹងពីការជ្រើសរើស
- ជូនដំណឹងដល់អ្នកដែលត្រូវសម្ភាសន៍
- ធ្វើការសម្ភាសន៍
- ប្រកាសលទ្ធផលនៃការជ្រើសរើស មិនលើសពី១ សប្តាហ៍បន្ទាប់ពីថ្ងៃប្រលង ឬសម្ភាសន៍រាយកាណ៍លទ្ធផលនៃការជ្រើសរើស  និងផ្ញើជូនមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទដើម្បីសម្រេច

## ❖ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

- ជាគ្រូបង្គោលផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទឃុំ

- ជាអ្នកផ្ដល់សេវាផ្សព្វផ្សាយព័ត៌មានបច្ចេកទេសកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ជាស្ពានចម្លងបញ្ហា ដំណោះស្រាយលើបច្ចេកទេសកសិកម្មពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬការិយាល័យផ្សព្វផ្សាយកសិកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទៅកសិករ និងជាអ្នកផ្ដល់ព័ត៌មានត្រឡប់ពីកសិករតាមរយៈការិយាល័យផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឬនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- ចូលរួមរៀបចំកសាងផែនការអភិវឌ្ឍន៍កសិកម្មឃុំ
- មានទំនាក់ទំនង និង សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានអង្គភាពជំនាញ អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- សម្របសម្រួលរៀបចំចងក្រងក្រុមកសិករដែលស្ម័គ្រចិត្ត និងជួយពង្រឹងក្រុមកសិករក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម
- ពង្រឹងសមត្ថភាពខ្លួនឯងតាមរយៈវគ្គបណ្ដុះបណ្ដាលទស្សនកិច្ចសិក្សា/ការអនុវត្តផ្ទាល់នៅទីវាល
- ចូលរួមសម្របសម្រួល និងដោះស្រាយបញ្ហាដែលកើតឡើងក្នុងផលិតកម្មកសិកម្ម
- គ្រប់គ្រងព័ត៌មានកសិកម្មក្នុងឃុំ។

## ❖ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន

- អនុវត្តគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ដែលនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានរៀបចំ
- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជ្រើសរើស និងបណ្ដុះ

បណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

- គាំទ្រ និងប្រើប្រាស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទឃុំដែលមានស្រាប់។

## ៥. សន្និដ្ឋាន

គោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃុំសម្រេចបានដោយមានការចូលរួមពីលោក លោកស្រី អ្នកនាងកញ្ញា ដែលជាថ្នាក់ដឹកនាំ មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើការពិគ្រោះយោបល់ និងបានរៀបចំសិក្ខាសាលាជាច្រើនលើក ដែលដឹកនាំដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ ការរួមវិភាគទានពីអ្នកពាក់ព័ន្ធជាទម្រង់ពហុភាគីនិយមជាធាតុចូលមួយដ៏មានសារៈសំខាន់ធ្វើឱ្យឯកសារនេះកាន់តែមានភាពសុក្រិតគ្រប់ជ្រុងជ្រោយ និងជាប្រទីបបំភ្លឺផ្លូវ ហើយក៏ជាខ្នាតគំរូដល់អ្នកអនុវត្តកម្មវិធី គម្រោងផ្សេង ៗ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន និងក្រសួងពាក់ព័ន្ធយកទៅអនុវត្តគោលការណ៍ណែនាំផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទឃុំប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងមានការទទួលខុសត្រូវប្រកបដោយវិជ្ជាជីវៈខ្ពស់នាពេលអនាគត។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ប្រធានបទបណ្តុះបណ្តាល

| ល.រ | ប្រធានបទ | ចំនួនម៉ោង |
|---|---|---|
| | **វិធីសាស្ត្រផ្សព្វផ្សាយ** | |
| ១ | លំនាំដើមនៃការផ្សព្វផ្សាយនៅកម្ពុជា | ៧ |
| ២ | ការកសាងផែនការសកម្មភាពផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧ |
| ៣ | ការតាមដាន និងវាយតម្លៃការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧ |
| ៤ | គេហទំព័រផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង<br>វិធីសាស្ត្រប្រើប្រាស់ | ៧ |
| ៥ | ការរៀនពីកសិករទៅកសិករ | ៧ |
| ៦ | យេនឌ័រក្នុងការងារផ្សព្វផ្សាយ និងការបង្កើនសិទ្ធិអំណាចដល់ស្ត្រី | ៧ |
| ៧ | ដំណើរការប្រាស្រ័យទាក់ទង | ១៤ |
| ៨ | ជំនាញសម្របសម្រួល និងការដឹកនាំក្រុម | ១៤ |
| ៩ | ការវាយតម្លៃតម្រូវការកសិករ | ៧ |
| ១០ | វិធីសាស្ត្រសរសេរករណីសិក្សា | ៧ |
| ១១ | ការចងក្រងបណ្តុំអាជីវកម្មកសិកម្ម និងផ្សារភ្ជាប់ឆ្ពោះទៅកាន់ទីផ្សារ | ៧ |
| **សរុប** | | **៩១** |
| | **ជំនាញបច្ចេកទេសដែលសមស្របជាមួយការប្រែប្រួលអាកាសធាតុ ការអនុវត្តកសិកម្មល្អ និងកសិកម្មវៃឆ្លាត** | |
| ១ | ទស្សនទាននៃការប្រែប្រួលអាកាសធាតុ និងកសិកម្មវៃឆ្លាតធន់និងអាកាសធាតុ | ៧ |
| ២ | ផលិតកម្មដំណាំ | ៤២ |
| ៣ | សាកវប្បកម្ម | ២២ |
| ៤ | ផលិតកម្ម និងបសុព្យាបាល | ៤២ |
| ៥ | ផលិតផល | ១៤ |
| ៦ | ព្រៃឈើ | ៧ |
| **សរុប** | | **១៣៤** |

**ឧបសម្ព័ន្ធទី២**

ទម្រង់ការជូនដំណឹងដល់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត**..................................

លេខ.................

ថ្ងៃ.........................ខែ.........ឆ្នាំ............. ព.ស ២៥៦......

................. ថ្ងៃទី.......... ខែ.........ឆ្នាំ២០.....................

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត**..................

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

<u>កម្មវត្ថុ៖</u> ស្តីពីការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ក្នុងស្រុក.................របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

<u>យោង៖</u> សៀវភៅគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោង ខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធាន មេត្តាជ្រាបថា៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត............................. ត្រូវដំណើរការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទឃុំ នៅក្នុងខែ.............ឆ្នាំ............ខាងមុខនេះតាមនីតិវិធី។ ដូច្នេះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្ត សូមជម្រាបជូនលោកប្រធាន ស្តីពីការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំនៅស្រុក............. ចំនួន................នាក់ដើម្បីអនុវត្តន៍តាម សៀវភៅគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ។

សេចក្តីដូចបានជម្រាបជូនខាងលើសូម លោកប្រធាន មេត្តាជ្រាបតាមការគួរនិងទទួលនូវការគោរពពីខ្ញុំបាទ។

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត**

<u>**ចម្លងជូន:**</u>

.........

**ឧបសម្ព័ន្ធទី៣**

ទម្រង់ការជូនដំណឹងជាសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត**.............

លេខ...........................

ថ្ងៃ.........................ខែ..........ឆ្នាំ............. ព.ស ២៥៦.......

.................. ថ្ងៃទី........... ខែ.............. ឆ្នាំ២០.......

**សេចក្តីជូនដំណឹង**
**ស្តីពីការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ**

**<u>យោង:</u>** -សៀវភៅគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ ។
- យោងតាមការចាំបាច់ក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតាមមូលដ្ឋាន

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត**..............
**សូមជូនដំណឹង**

ដល់ប្រជាពលរដ្ឋក្នុងស្រុក....................ខេត្ត.................ទាំងពីរភេទអោយបានជ្រាបថា៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ...................... នឹងជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំចំនួន.......នាក់ក្នុងមួយឃុំនៅស្រុក...............ខេត្ត.................. ដែលមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

❖ **លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ៖**

បេក្ខជន បេក្ខនារីដែលត្រូវជ្រើសរើស និងបណ្តុះបណ្តាលក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវមានលក្ខណៈសម្បត្តិមួយចំនួនដូចខាងក្រោម៖

១.ជនជាតិខ្មែរ មានអាយុចាប់ពី១៨ឆ្នាំឡើង
២.កម្រិតវប្បធម៌ទាបបំផុត មធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ)
៣.មានទីលំនៅពិតប្រាកដនៅក្នុងភូមិ ឃុំគោលដៅ
៤.ជាភ្នាក់ងារសុខភាពសត្វភូមិ
៥.គ្រូបង្គោល ឬគ្រូ វិធានការចម្រុះគ្រប់គ្រងដំណាំ( IPM)
៦.មានវិញ្ញាបនបត្របញ្ជាក់ការសិក្សាពាក់ព័ន្ធការងារកសិកម្ម

៧.ស្ម័គ្រចិត្តបម្រើការងារផ្សព្វផ្សាយកសិកម្មតាមរយៈការចែករំលែកចំណេះដឹងនិងបទពិសោធន៍ជាមួយអ្នកភូមិ។

❖ **<u>សំគាល់</u>** ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួមជ្រើសរើសជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ។

ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក.............និងឃុំគោលដៅឃុំខាងលើបើមានបំណងចង់បម្រើការងារជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំសូមអញ្ជើញមកទទួល និងដាក់ពាក្យនៅ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត..........រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី.........ខែ..........ឆ្នាំ២០.. ដែលជាថ្ងៃកំណត់ចុងក្រោយនៃកាលបរិច្ឆេទឈប់ទទួលពាក្យ ( ពាក្យសុំចូលបម្រើការងារនិងគំរូប្រវត្តិរូបត្រូវបានចែកជូនដោយឥតគិតថ្លៃ ) មានចែកនៅតាមស្រុកគោលដៅ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត............រាល់ម៉ោងធ្វើការ ។

កន្លែងទទួលពាក្យនៅការិយាល័យរដ្ឋបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត លេខទំនាក់ទំនង៖

សំណុំបែបបទដែលបេក្ខជន/បេក្ខនារី ត្រូវបំពេញ និងភ្ជាប់មកជាមួយមាន៖

- ជីវប្រវត្តិសង្ខេបផ្ទាល់ខ្លួនមានបិទរូបថត ( ៤ គុណ ៦ ) ចំនួន០២ច្បាប់
- សញ្ញាបត្របច្ចេកទេសជំនាញ ឬវិញ្ញាបនបត្រមានតម្លៃស្មើ ចំនួន០២ច្បាប់
- សញ្ញាបត្រចំណេះទូទៅ ចំនួន០២ច្បាប់
- សេចក្តីបញ្ជាក់របស់លោកមេឃុំ ចំនួន០២ច្បាប់
- អត្តសញ្ញាណប័ណ្ណសំគាល់ខ្លួន ចំនួន០២ច្បាប់

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត**

**<u>កន្លែងបិទផ្សាយ</u>**

- រដ្ឋបាលខេត្ត.................
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត................
- រដ្ឋបាលស្រុក និងការិ.កសិកម្មស្រុក..............................
- សាលាឃុំគោលដៅរបស់ ស្រុក..........................
- ឯកសារ- កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ៤**

ទម្រង់បញ្ជីឈ្មោះបេក្ខជនប្រឡង

# បញ្ជីឈ្មោះបេក្ខជនប្រឡង

នៅថ្ងៃទី............ខែ................ឆ្នាំ២០......

ទីកន្លែង...................................................................

| ល.រ | លេខតុ | នាម-គោត្តនាម | ភេទ | ទីលំនៅបច្ចុប្បន្ន | | | ឃុំគោលដៅ | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ភូមិ | ឃុំ/សង្កាត់ | ក្រុង/ស្រុក | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

* **កំណត់សំគាល់៖** បេក្ខជនប្រឡងសរុប = .........នាក់, ស្ត្រី=...........នាក់

......... ថ្ងៃទី............ខែ..............ឆ្នាំ២០......

......... ថ្ងៃទី..........ខែ.........ឆ្នាំ២០........

**មន្ត្រីរដ្ឋបាល**

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**ឧបសម្ព័ន្ធទី ៥**

ទម្រង់សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការប្រលងជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**.........

លេខ:..........................

ថ្ងៃ..........................ខែ..........ឆ្នាំ.............. ព.ស ២៥៦.......

.................. ថ្ងៃទី........... ខែ.............. ឆ្នាំ២០.......

**សេចក្តីជូនដំណឹង**

**ស្តីពី**

**កាលបរិច្ឆេទនៃការប្រលងជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត...................សូមជម្រាបជូនដំណឹងដល់បេក្ខជន បេក្ខនារីដែលបានដាក់ពាក្យសុំបម្រើការងារជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ នៅស្រុក.................. ទាំងអស់ឱ្យបានជ្រាបថា៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត..................បានកំណត់ទីកន្លែង និងកាលបរិច្ឆេទសម្រាប់ការប្រលងជ្រើសរើសភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំដូចខាងក្រោមនេះ៖

១) ប្រលងលើវិញ្ញាសារសរសេរនឹងប្រព្រឹត្តទៅនៅថ្ងៃទី.......................ខែ....................ឆ្នាំ........................ វេលាម៉ោងនៅ......................។

២) ការប្រលងផ្ទាល់មាត់នឹងប្រព្រឹត្តទៅនៅថ្ងៃទី............ខែ...............ឆ្នាំ...............វេលាម៉ោង.................. នៅ ...............................................។

<u>ភ្ជាប់តារាងបញ្ជីឈ្មោះបក្ខជន៖</u>

បេក្ខជនទាំងពីរភេទអាចទៅពិនិត្យឈ្មោះដែលមាននៅ..................ឬ...........................។

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**<u>ចម្លងជូន៖</u>**

រដ្ឋបាលស្រុក...........

"ដើម្បីជូនជ្រាប"

ការិ-កសិកម្មស្រុក..........

"ដើម្បីផ្សព្វផ្សាយ"

**ឧបសម្ព័ន្ធទី ៦**

ទម្រង់បញ្ជីរាយនាមបេក្ខជនបេក្ខនារីដែលប្រលងជាប់ជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត.................**

**បញ្ជីរាយនាមបេក្ខជន**

**ប្រលងជាប់ជាភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ**

**នៅថ្ងៃទី.....................ខែ.................. ឆ្នាំ២០......**

| ល.រ | នាម-គោត្តនាម | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | ទីលំនៅបច្ចុប្បន្ន | លេខបន្ទប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

បានបញ្ចប់បញ្ជីឈ្មោះត្រឹមលេខរៀង.........ក្នុងនោះមានប្រុស...........នាក់ ស្រី............នាក់

ថ្ងៃ....................ខែ..........ឆ្នាំ.......... ព.ស ២៥៦...

.......... ថ្ងៃទី...........ខែ............ឆ្នាំ២០.......

**អ្នកធ្វើតារាង**

ថ្ងៃ....................ខែ..........ឆ្នាំ.......... ព.ស ២៥៦...

.......... ថ្ងៃទី...........ខែ............ឆ្នាំ២០.......

បានឃើញ និងឯកភាព

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់និងនេសាទ**

**ឧបសម្ព័ន្ធទី ៧**

ទម្រង់ពាក្យសុំចូលបម្រើការងារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**

**លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត**

**កម្មវត្ថុ** ៖សំណើសុំដាក់ពាក្យចូលបម្រើការងារជា.................................................................................

**តាមរយៈ:** ៖ លោក/លោកស្រី មេឃុំ........................................................................................................

យោងតាមកម្មវត្ថុខាងលើខ្ញុំបាទ/នាងខ្ញុំចង់បម្រើការជា...............................................................

នៅ............................................... ស្រុក/ក្រុង ..................................... ខេត្ត ....................................។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងគោរពរាល់បទបញ្ជា និងលក្ខខណ្ឌការងារទាំងឡាយដែលមាននៅក្នុងកិច្ចសន្យាការងារដែលតម្រូវឲ្យខ្ញុំបាទ/នាងខ្ញុំអនុវត្តបន្ទាប់ពីត្រូវបានជ្រើសរើស។

សូមភ្ជាប់មកជាមួយនូវ៖

១. ប្រវត្តិសង្ខេបផ្ទាល់ខ្លួនមានបិទរូបថត (៤ x ៦) ចំនួន ០២ ច្បាប់

២. ឯកសារយោង (សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ និងសញ្ញាបត្រ..) ចំនួន ០២ ច្បាប់

៣. រូបថត ៤ x ៦ ចំនួន ០២ ច្បាប់

អាស្រ័យដូចបានរៀបរាប់ជម្រាបជូនខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមលោកប្រធានមេត្តាទទួលដោយក្តីអនុគ្រោះ។

សូមលោកប្រធាន មេត្តាទទួលនូវ ការគោរពអំពីខ្ញុំបាទ/នាងខ្ញុំ

ធ្វើនៅ........................,ថ្ងៃទី.........ខែ..........ឆ្នាំ ២..........

ហត្ថលេខានិងឈ្មោះសាមីខ្លួន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រវត្តិរូបសង្ខេប

នាម និងគោត្តនាម

_ អក្សរខ្មែរ ............................................................................................................................................

_ អក្សរឡាតាំង ........................................................................................................................................

_ ភេទ .......................ជនជាតិ...........................សាសនា....................................................................

_ ទីកន្លែងកំណើត ភូមិ...................ឃុំ/សង្កាត់......................... ស្រុក/ក្រុង......................ខេត្ត.........................

_ ទីលំនៅបច្ចុប្បន្នភូមិ.................ឃុំ/សង្កាត់.................... ស្រុក/ក្រុង.................ខេត្ត..................................

_ កម្រិតវប្បធម៌.............................................................កម្រិតជំនាញភាសា......................................................

_ កម្រិតជំនាញបច្ចេកទេស..........................................រយៈពេលសិក្សា.......................................................

_ មុខរបរសព្វថ្ងៃ.........................................................................................................................................

_ លេខទូរស័ព្ទ...................................................អ៊ីម៉ែល............................................................................

# ស្ថានភាពគ្រួសារ

_ ឪពុកឈ្មោះ...................................................អាយុ..................................ស្លាប់ ឬ រស់.............................

_ ម្ដាយឈ្មោះ...................................................អាយុ..................................ស្លាប់ ឬ រស់.............................

_ មុខរបរ.......................................ទីលំនៅបច្ចុប្បន្ន.............................................................................

_ ប្រពន្ធឈ្មោះ..................................................អាយុ......................មុខរបរ............................................

_ ទីលំនៅបច្ចុប្បន្ន.......................................................................................................................................

_ កូនមាន៖...........................នាក់៖ ប្រុស...............................នាក់/ ស្រី....................................នាក់

    _ កូនទី១ ឈ្មោះ....................................ភេទ........អាយុ..........ឆ្នាំ មុខរបរ...............................

    _ កូនទី២ ឈ្មោះ....................................ភេទ........អាយុ..........ឆ្នាំ មុខរបរ...............................

    _ កូនទី៣ ឈ្មោះ....................................ភេទ........អាយុ..........ឆ្នាំ មុខរបរ...............................

## បងប្អូនបង្កើត

_ ឈ្មោះ..........................................ភេទ..........អាយុ...............ឆ្នាំ មុខរបរ.......................................

_ ឈ្មោះ..........................................ភេទ..........អាយុ...............ឆ្នាំ មុខរបរ.......................................

_ ឈ្មោះ..........................................ភេទ..........អាយុ...............ឆ្នាំ មុខរបរ.......................................

_ ឈ្មោះ..........................................ភេទ..........អាយុ...............ឆ្នាំ មុខរបរ.......................................

## រយៈពេល សិក្សារៀនសូត្រ បំពាក់បំប៉ន បំពេញការងារ និងបទពិសោធន៍តាមដំណាក់កាល

រយៈពេលសិក្សារៀនសូត្រ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

វគ្គបំពាក់បំប៉ន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

បទពិសោធន៍ការងារ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

តើធ្លាប់មានបទពិសោធន៍ក្នុងការប្រើប្រាស់កុំព្យូទ័រដែរឬទេ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

តើធ្លាប់មានបទពិសោធន៍ក្នុងការប្រើប្រាស់អ៊ីនធើណេតដែរឬទេ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

បញ្ជាក់អះអាងពីប្រវត្តិរូប ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ធ្វើនៅ...................... ថ្ងៃទី..........ខែ...................ឆ្នាំ............

ហត្ថលេខា និងឈ្មោះសាមីខ្លួន

| ទម្រង់វាយតម្លៃលទ្ធផលបំពេញការងាររបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឃុំ(#3.c) | |
|---|---|
| **ផ្នែកទី១ ៖ ព័ត៌មានទូទៅ** | |
| ឈ្មោះ ............................................................... | មុខតំណែង:.................................................. |
| កាលបរិច្ឆេទចូលបម្រើការងារ:........................................ | កាលបរិច្ឆេទវាយតម្លៃ:........................................ |
| រាជធានី/ខេត្ត:...........................................................<br>ក្រុង/ស្រុក/ខណ្ឌ.......................................................<br>ឃុំ.......................................................................... | អ្នកសម្របសម្រួល:............................................ |

**ផ្នែកទី២ ៖ ការវាយតម្លៃ**

| សូមពិនិត្យពិន្ទុឱ្យបានសមស្រប (✓)<br>(ពិន្ទុអប្បបរមា១-អតិបរមា៤) | | ត្រូវការកែលម្អ | មធ្យម | ល្អ | ល្អណាស់ | ពិន្ទុវាយតម្លៃខ្លួនឯង | ពិន្ទុប្រធានអង្គភាព | ពិន្ទុអធិបតីជន | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ក | ខ | គ | ឃ | ង |
| | | | | | | | | | | | | |
| **១. ជំនាញបច្ចេកទេស** | | | | | | | | | | | | |
| ១.១ | ចំណេះដឹងនិងកម្រិតនៃផ្នែរការយល់ដឹងអំពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលជន់ទៅនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| ១.២ | ជំនាញក្នុងការសម្របសម្រួល | | | | | | | | | | | |
| ១.៣ | ជំនាញក្នុងការសរសេរនិងការធ្វើរបាយការណ៍ | | | | | | | | | | | |
| ១.៤ | ជំនាញក្នុងការធ្វើបទបង្ហាញ ឬបកស្រាយ | | | | | | | | | | | |
| **សរុបរង (១)** | | | | | | | | | | | | |
| **២. គំនិតផ្តួចផ្តើម** | | | | | | | | | | | | |
| ២.១ | ប៉ិនប្រសព្វថ្លៃប្រឌិតក្នុងការផ្តល់ព័ត៌មានបច្ចេកទេសសមស្របថ្មីៗ និងចាំបាច់ | | | | | | | | | | | |
| ២.២ | មានគំនិតយោបល់ល្អៗ និងថ្មីៗសម្រាប់អនុវត្តការងារអោយប្រសើរ | | | | | | | | | | | |
| **សរុបរង (២)** | | | | | | | | | | | | |
| **៣. ការទំនាក់ទំនង និងសម្របសម្រួល** | | | | | | | | | | | | |
| ៣.១ | ជំនាញក្នុងការស្តាប់ និងផ្តល់ព័ត៌មានត្រឡប់ | | | | | | | | | | | |
| ៣.២ | ជំនាញក្នុងការសង្កេត | | | | | | | | | | | |
| ៣.៣ | ការចែករំលែកចំណេះដឹងប្រកបដោយប្រសិទ្ធិភាព | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | **សរុបរង (៣)** | | | | | | | | | | | |
| **៤. ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ** | | | | | | | | | | | | |
| ៤.១ | អាកប្បកិរិយា | | | | | | | | | | | |
| ៤.២ | ការចូលរួម | | | | | | | | | | | |
| ៤.៣ | កាបន្សាំខ្លួន និងការបត់បែន | | | | | | | | | | | |
| ៤.៤ | ការចូលរួមធ្វើការងារជាក្រុម | | | | | | | | | | | |
| ៤.៥ | មានឆន្ទៈចំពោះគោលការណ៍សមភាពយេនឌ័រ | | | | | | | | | | | |
| | **សរុបរង (៤)** | | | | | | | | | | | |
| **៥. ការយកចិត្តទុកដាក់ក្នុងការងារ** | | | | | | | | | | | | |
| ៥.១ | គុណភាព និងការយកចិត្តទុកដាក់លើការងារ | | | | | | | | | | | |
| ៥.២ | មានលទ្ធភាពទទួលខុសត្រូវនិងចែករំលែកការងារ | | | | | | | | | | | |
| ៥.៣ | ភាពទៀងទាត់តាមម៉ោងលើការងារ | | | | | | | | | | | |
| ៥.៤ | សមត្ថភាពក្នុងការផ្តល់សេវាអនុវត្តការងារថ្នាក់ឃុំ (កម្មវិធី ឬគម្រោង) | | | | | | | | | | | |
| ៥.៥ | មានការតាមដាន និងគាំទ្រការអនុវត្តសកម្មភាព | | | | | | | | | | | |
| ៥.៦ | រៀបចំ និងចងក្រងរបាយការណ៍ | | | | | | | | | | | |
| | **សរុបរង (៥)** | | | | | | | | | | | |
| | **សរុបរួម (១+២+៣+៤+៥)** | | | | | | | | | | | |

**ផ្នែកទី៣ ៖ មតិយោបល់សាមីខ្លួន**

**យោបល់ និង ទស្សនៈរបស់សាមីខ្លួន ៖** ...........................................................................................................

.............................................................................................................................................

.............................................................................................................................................

**តម្រូវការការបណ្ដុះបណ្ដាល៖**..................................................................................................................

.............................................................................................................................................

.............................................................................................................................................

**ផ្នែកទី៤ ៖ មតិយោបល់របស់ប្រធានអង្គភាព/ស្ថាប័ន**

| |
|---|
| យោបល់៖<br>....................................................................................................<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| អនុសាសន៍ដែលត្រូវធ្វើការកែលម្អនាពេលអនាគត គោលបំណង និងពេលវេលា៖<br>....................................................................................................<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| **ផ្នែកទី៥ ៖ ចំណាប់អារម្មណ៍របស់កសិករ**<br>១=☹ ៖.......................................................................នាក់<br>២=😐 ៖.......................................................................នាក់<br>៣=☺ ៖.......................................................................នាក់<br>៤=♥ ៖.......................................................................នាក់ |

| ឈ្មោះ | មុខដំណែង | កាលបរិច្ឆេទ | ហត្ថលេខា |
|---|---|---|---|
| ប្រធានអង្គភាព | | | |
| សាមីខ្លួន | | | |
| អ្នកសម្របសម្រួល | | | |

# ឯកសារយោង

១. គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ឆ្នាំ២០១៥

២. យុទ្ធសាស្ត្រធនធានមនុស្សសម្រាប់ការផ្សព្វផ្សាយកសិកម្ម ឆ្នាំ២០១៨

៣. គោលការណ៍ណែនាំស្តីពីការរៀនសូត្រពីកសិករទៅកសិករ និងការផ្សារភ្ជាប់ផលិតផលកសិកម្មទៅទីផ្សារឆ្នាំ២០១៨។

អាសយដ្ឋាន : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០៧៧ ៥១៤ ០៥១

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម/*Department of Agricultural Extension*

គេហទំព័រ : http://www.khmeragri-info